# ទន្លេមេគង្គពីខេត្តក្រចេះដល់ប្រទេសឡាវ A1 & A2



| | | |
|---|---|---|
| **ខេត្ត** | : | ស្ទឹងត្រែង និង ក្រចេះ |
| **ស្រុក** | : | ថាឡាបរិវ៉ាត់ ស្ទឹងត្រែង សៀមបូក និង សម្បូរ |
| **ផ្ទៃដី ( ហិកតា)** | : | ៨៣.៥០១ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ២១ ដល់ ១៨៩ |
| **កូអរដោនេចំណុចកណ្ដាល** | : | ១៣°១៧'ជ ១០៥°៥៨'ក |

### ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានទន្លេមេគង្គ និង រុក្ខជាតិដុះជាប់ៗមាត់ទន្លេ ពីទីរួមខេត្តក្រចេះរហូតដល់ព្រំដែនប្រទេសឡាវ ។ ទន្លេមេគង្គមានសភាពខុសៗគ្នានៅតាមបណ្ដោយទន្លេនៃការលាតសន្ធឹងរបស់វា ផ្នែកខ្លះមានចង្អូរផ្លូវទឹកតែមួយដែលមានទទឹងរហូតដល់១,៥ម៉ែត្រ និង ពោរពេញទៅដោយផ្ទៃទឹក រីឯផ្នែកខ្លះផ្សេងទៀតមានចង្អូរផ្លូវទឹកហូរជាច្រើន និង កោះតូចៗ ។ នៅកន្លែងដែលមានចង្អូរផ្លូវទឹកហូរច្រើនមានវត្តមានរុក្ខជាតិដុះនៅលើកោះតូចៗទាំងនោះយ៉ាងលើសលប់ និង លិចទឹកតាមពេលវេលា ហើយព្រៃគុម្ពោត និង ដើមឈើមួយចំនួនដុះក្នុងលក្ខណៈប្រមូលផ្ដុំគ្នាក្នុងទន្លេ ដែលបានលិចទឹកនៅតែចុងៗស្ទើរតែពេញមួយរដូវវស្សា ហើយប្រភេទទីជំរកសំខាន់ៗផ្សេងទៀត រួមមានវាលខ្សាច់ និង ថ្មនៅក្នុងទន្លេ ។ ទោះជាមានការថយចុះនៃព្រៃឈើដែលដុះតាមប្រព័ន្ធទន្លេខ្លះក៏ដោយ ក៏តំបន់មួយចំនួននៅមានព្រៃពាក់កណ្ដាលស្រោង និង ព្រៃរបោះស្ថិតក្នុងស្ថានភាពល្អនៅត្រង់ព្រំប្រទល់រវាងខេត្តក្រចេះ និង ខេត្តស្ទឹងត្រែង ។ បន្ទាប់មាត់ពីទន្លេ ព្រៃឈើមានលក្ខណៈជាព្រៃរបោះ ហើយនៅតាមមាត់ទន្លេមានការបោះទីតាំងរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើកសិកម្មពនេចរ ។ ទន្លេមេគង្គចាប់ពីត្រង់ចំណុច ៥គីឡូម៉ែត្រ ខាងជើងទីរួមខេត្តស្ទឹងត្រែងរហូតដល់ព្រំដែនប្រទេសកម្ពុជា-ឡាវត្រូវបានដាក់បញ្ចូលជាតំបន់រ៉ាមសារ ។

តំបន់នេះបានទ្រទ្រង់ប្រភេទខ្ចប់ដីមេគង្គមានចំនួនច្រើនជាងគេក្នុងពិភពលោក ដែលថ្មីៗនេះគេហៅប្រភេទនេះថាជាប្រភេទមានតែនៅក្នុងតំបន់ទន្លេមេគង្គផ្នែកខាងលើ និង ដៃសំខាន់ៗរបស់វា ។ លើសពីនេះទៀត តំបន់នេះបានទ្រទ្រង់នូវពពួកនៅតាមតំបន់ទន្លេ ដែលចំនួនវាបានថយចុះយ៉ាងខ្លាំងនៅតំបន់អាស៊ីអគ្នេយ៍ រួមមានត្រដេវរីចទន្លេ សត្វជង្គង់ក្រាស់ចំពុះខ្មៅ និង រំពេទន្លេ ក្រៅពីនេះនៅមានប្រភេទទទួលរងការគំរាមកំហែង និង ជិតរងគ្រោះក្នុងពិភពលោក ដែលគេបានកត់ត្រាពីតំបន់នេះដូចជាត្មាតផេះ ត្មាតភ្លើង និង ស្មោញ ។ ចំនួនតិចតួចនៃប្រភេទត្រយ៉ងចំកំកសត្រូវបានកត់ត្រានៅតាមបណ្ដោយទន្លេត្រង់ផ្នែកដែលមានព្រៃឈើដុះ ។ ជាចុងក្រោយ តំបន់នេះអាចជាតំបន់មួយដែលនៅសេសសល់ក្រោយគេក្នុងចំណោមតំបន់ទាំងឡាយក្នុងតំបន់ឥណ្ឌូចិន ដែលបានទ្រទ្រង់ប្រភេទរំពេពោះខ្មៅ ទោះជាមានពតិមានតិចតួច និង មានការបញ្ជាក់ពីការពងកូននាពេលបច្ចុប្បន្ននេះក៏ដោយ ។ ជាប្រវត្តិសាស្ត្រ តំបន់នេះបានទ្រទ្រង់ប្រភេទរំពេចំពុះវែងខ្ចី ដែលមានការកត់ត្រាចុងក្រោយជាច្រើនគូនៅតាមបណ្ដោយទន្លេក្នុងឆ្នាំ ១៩៣២ ហើយតាមរយៈការសិក្សាស្រាវជ្រាវនាពេលថ្មីៗ ប្រភេទនេះមិនបានជួបប្រទះឡើយទំនងជាវាបានផុតពូជពីទន្លេមេគង្គទៅហើយ ។

### ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| ខ្ចប់ដីមេគង្គលើ | Mekong Wagtail | *Motacilla samveasnae* | A1 | A2 |

| | | | | |
|---|---|---|---|---|
| ត្មាតផេះ | White-rumped Vulture | *Gyps bengalensis* | A1 | |
| ត្មាតភ្លើង | Red-headed Vulture | *Sarcogyps calvus* | A1 | |
| ត្រយ៉ងចំកំក ស | White-shouldered Ibis | *Pseudibis davisoni* | A1 | |
| ទន្រ្ទីតទន្លេ | Small Pratincole | *Glareola lactea* | | A4i |
| រំពេពោះខ្មៅ | Black-bellied Tern | *Sterna acuticauda* | A1 | |
| ស្មោញ | Darter | *Anhinga melanogaster* | A1 | |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 | |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបពីរប្រភេទរស់ក្នុងប្រភេទព្រៃរបោះ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

ស្វាក្តាម ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

ក្រពើទន្លេ (ក្រពើត្រី) និង កន្ធាយក្បាលបង្កែប ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការគំរាមកំហែងធ្ងន់ធ្ងរបំផុតលើពពួកសត្វរស់នៅតាមដងទន្លេ គឺការប្រមាញ់ ការប្រមូលយកពងកូន និង ការរំខានដោយសកម្មភាពមនុស្សនៅលើតំបន់វាលខ្សាច់ក្នុងអំឡុងពេលរដូវពងកូន ។ ការគំរាមកំហែងធ្ងន់ធ្ងរផ្សេងទៀតគឺការកាប់ព្រៃឈើ និង ការរានដីព្រៃសម្រាប់ធ្វើកសិកម្មនៅតាមបណ្តោយមាត់ទន្លេ ។ ការនេសាទខុសច្បាប់ ជាពិសេសការប្រើប្រាស់ថ្នាំពុល និង គ្រឿងផ្ទុះគឺជាមូលហេតុមួយដែលគួរឱ្យព្រួយបារម្ភ ។ ការគំរាមកំហែងដែលនឹងធ្វើឱ្យមហន្តរាយធ្ងន់ធ្ងរនាពេលអនាគតគឺជាការសាងសង់នៃគំរោងវារីអគ្គិសនីធំៗ និង ការអភិវឌ្ឍន៍ផ្លូវនាវាចរណ៍តាមបណ្តោយដងទន្លេមេគង្គ និង ដៃទន្លេធំៗរបស់វា ។

**អនុសាសន៍**

ការអភិរក្សដងទន្លេមេគង្គដែលបានដាក់បញ្ចូលទៅក្នុងតំបន់រ៉ាមសារ គឺជាអាទិភាពសំខាន់មួយ ។ ប្រវែងទាំងមូលនៃទន្លេមេគង្គនៅក្នុងតំបន់ IBA គួរតែរៀបចំការអភិរក្ស ហើយផ្តោតតែលើផ្នែកតូចៗនៅដាច់ៗពីគ្នា ដែលអាចទទួលរងផលប៉ះពាល់រហូតនាំឱ្យមានភាពមហន្តរាយ ។

ការសិក្សាស្រាវជ្រាវចាំបាច់ត្រូវធ្វើឡើងបន្ថែមទៀត ដោយផ្តោតលើការកំណត់នៃផ្នែកសំខាន់ៗរបស់ព្រៃឈើប្រព័ន្ធទន្លេ និង ព្រែក អូរនានា ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់នូវទីតាំង និង ចំនួនប្រភេទសត្វដែលពងកូនលើវាលខ្សាច់ ។

ការប្រឹងប្រែងត្រូវតែធ្វើឡើង ដើម្បីការពារប្រភេទសត្វស្លាបដែលពងកូនលើវាលខ្សាច់ ខណៈដែលពួកវាកំពុងពងកូន។ កិច្ចព្រមព្រៀងសហគមន៍អាចបង្កើតឡើងតាមភូមិនិមួយៗ ដើម្បីកុំឱ្យតំបន់ទាំងនោះមានការរំខាន ។

ការបង្កើតភូមិថ្មីៗ និង ការអភិវឌ្ឍន៍កសិកម្មតាមដងទន្លេមិនគួរត្រូវបានលើកទឹកចិត្តឡើយ ហើយផ្នែកសំខាន់ៗដែលមានព្រៃឈើប្រព័ន្ធទន្លេ គួរតែការពារឱ្យបានតឹងរឹងពីការកាប់រំលំ និង ការធ្វើកសិកម្មពនេចរ ។

សកម្មភាពគ្រប់គ្រង និង អភិរក្សនៃប្រភេទសត្វព្រៃ ព្រមទាំងត្រីសំខាន់ៗ គួរតែបង្កើតឱ្យមានឡើងនៅក្នុងតំបន់ IBA នេះ។

### ឯកសារយោង

Davidson, P., Poole, C. M. and Duckworth J. W. (2001) Mekong Wagtail (*Motacilla samvaesnae*): the great river's only known avian endemic. *Bull. Oriental Bird Club* 34: 56-59.

Davies, J. D. (1994) *Wetland surveys in Cambodia to identify sites of international importance.* Kuala Lumpur: Asian Wetland Bureau.

Duckworth, J. W., Alström, P., Davidson, P., Evans, T. D., Poole, C. M., Tan Setha and Timmins, R. J. (2001) A new species of wagtail from the lower Mekong basin. *Bull. Brit. Ornith. Club* 121(3): 152-182.

Mundkur, T., Carr, P., Sun Hean and Chhim Somean (1995) *Surveys for large waterbirds in Cambodia, March-Apri l 1994.* Cambridge, UK: IUCN/SSC.

Poole, C. M. Duckworth, J. W. and van Zalinge, N. J. (in prep.) Bird observations from the Mekong and major tributaries in north-east Cambodia, 1998-2000.

Tan Setha (2002) Mekong Wagtail: a species new to science discovered in northeast Cambodia. *Cambodia Bird News* : 9: 14-17.

Timmins, R. J. and Men Soriyun (1998) *A wildlife survey of the Tonle San and Tonle Srepok river basins in north-east ern Cambodia.* Hanoi and Phnom Penh: Fauna & Flora International and the Wildlife Protection Office.

Thomas, W.W. 1964. *A preliminary list of the birds of Cambodia*. Unpubl.

van Zalinge, N. J., Poole, C. M., Duckworth, J. W. and Goes, F. (2002) Waterbird counts on the Mekong, Sekong, Sesan and Srepok rivers. *Cambodia Bird News* 9: 18-29.